# មេរៀនទី ៣៨: កំណើតរបស់អ៊ីសាក

## លោកុប្បត្តិ ២១:១-៦

**គោលបំណង៖** ព្រះសន្យានាំនូវក្តីអំណរឲ្យដល់យើង។

**ខគម្ពីរចងចាំ៖ ភីលីព** ៤:៤ *“ចូរអរសប្បាយ ក្នុងព្រះអម្ចាស់ជានិច្ច ខ្ញុំប្រាប់ម្តងទៀតថា ចូរអរសប្បាយឡើង។”*

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**

ព័ន្ធកិច្ចរបស់ព្រះគឺច្បាស់លាស់ណាស់ ប៉ុន្តែព្រះអង្គជ្រាបដឹងថាតើត្រូវមានអំណរដោយរបៀបណាផងដែរ។ សូមរំឭកឡើងវិញពីអំណោយមួយចំនួនដែលព្រះបានប្រទានមកដល់យើង។ តើអំណោយទាំងនោះបាននាំមកនូវក្តីអំណរដល់អ្នកដូចម្តេចខ្លះ? ប្រហែលជាអំណោយទាំងនោះអាចជាការឆ្លើយតបរបស់ព្រះចំពោះអ្វីដែលអ្នកបានអធិស្ឋាន ឬអ្វីដែលអ្នកមិនដែលបានទូលសូមពីព្រះសោះក៏ថាបាន។ ព្រះពេញចិត្តនឹងប្រទានអំណោយដែលអាចពង្រឹង និងលើកទឹកចិត្តតាមវិធីផ្សេងៗ។ សូមសរសេរអំណោយទាំងនោះ ហើយអធិស្ឋានដោយអំណរ និងរក្សាអំណោយទាំងនោះនៅទីណាដែលនឹងរំលឹកយើងពីក្តីអំណរនៃអំណោយរបស់ព្រះ។

**ចំរៀង៖** ១. ខ្ញុំសប្បាយរីករាយ ២.បើអ្នកសប្បាយក្នុងព្រះយេស៊ូវ ៣. ព្រះនឹងរៀបចំផ្លូវ

**១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបើក)*

**២. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

### ៣. ល្បែងកំសាន្ត «ធ្វើឲ្យសើច»



១. ចែកកុមារជា ២ ក្រុមគឺក្រុម ក និងខ

២. ក្រុម ក នឹងជ្រើសរើសកុមារណាម្នាក់មកធ្វើជាអ្នកធ្វើកាយវិការ តែមិនត្រូវបញ្ចេញសម្លេងនោះទេ។ គ្រូត្រូវកំណត់នាទីក្នុងការធ្វើកាយវិការ ប្រសិនបើសមាជិកក្រុម ខ ណាម្នាក់សើច នោះក្រុម ក នឹងឈ្នះល្បែងនេះ។




៣. ប្រសិនបើក្រុម ខ មិនសើចទេ នោះ ក្រុម ក និងចាញ់ល្បែងនេះ។

៤. បន្តលេងល្បែងនេះ ដោយប្តូរអ្នកធ្វើកាយវិការ។

៥. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា យើងអាចនឹង សើចសប្បាយបានពីព្រោះព្រះប្រទានក្តីអំណរឲ្យដល់យើង។

### ៤. ការណែនាំមេរៀន

នៅពេលដែលអ្នកណាម្នាក់ជូនអំណោយដល់អ្នក តើអ្នកមានអារម្មណ៍ដូចម្តេច? អ្នកមានអារម្មណ៍រីករាយទេ? ជាគ្រីស្ទបរិស័ទដែលមានជំនឿលើព្រះ មានហេតុផលជាច្រើនដែលធ្វើឲ្យយើងមានអំណរ។ ថ្ងៃនេះយើងនឹងមកស្វែងយល់អំពីលោកអ័ប្រាហាំ និង សារ៉ា ដែលពួកគេមានអំណរជាខ្លាំងនៅពេលដែលព្រះបានប្រទានអំណោយវិសេសមួយដល់ពួកគេ។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

រឿងនៅក្នុងព្រះគម្ពីររបស់យើងគឺនិយាយពី អ័ប្រាហាំ និងសារ៉ា។ ពួកគេបានរង់ចាំស្ទើរមួយជីវិតរបស់គេដើម្បីមានកូនម្នាក់ ហើយព្រះបានសន្យាជាមួយអ័ប្រាហាំថាគាត់នឹងមានកូនម្នាក់ តាំងពីគាត់នៅមានអាយុ ៧៥ ឆ្នាំ។ ប៉ុន្តែអស់ពេលជាច្រើនឆ្នាំកន្លងទៅ អ័ប្រាហាំ និង សារ៉ានៅតែមិនទាន់មានកូន។ នៅជំនាន់នោះ ការមិនមានកូនគឺជារឿងអាម៉ាស់មួយ ដូច្នេះយើងអាចមើលឃើញថា អ័ប្រាហាំ និង សារ៉ា ពិតជាចង់បានកូនខ្លាំងណាស់។ ប៉ុន្តែអ័ប្រាហាំនៅតែមានជំនឿលើព្រះថាទ្រង់តែងតែរក្សាពាក្យសន្យារបស់ព្រះអង្គ។

នៅទីបំផុត ព្រះបានប្រទានកូនប្រុសដល់ សារ៉ា និងអ័ប្រាហាំ នៅពេលដែលសារ៉ាមានអាយុ៩០ឆ្នាំ ហើយអ័ប្រាហាំមានអាយុ ១០០ឆ្នាំ! តើអ្នកអាចស្រមៃមើលថា ជីដូនចំណាស់អាយុ៩០ឆ្នាំអាចមានកូនបាន? រឿងនេះមើលទៅគឺមិនអាចទៅរួចទេសំរាប់មនុស្ស ប៉ុន្តែព្រះគឺពេញដោយអំណាច ហើយព្រះអាចធ្វើឲ្យអ្វីៗដែលមិនអាចទៅរួចឲ្យកើតឡើងបាន។

អ័ប្រាហាំ និង សារ៉ាមានចិត្តរីករាយខ្លាំងណាស់។ នៅពេលកូនរបស់គេបានកើតមក ពួកគេមានអំណរជាខ្លាំង ដូច្នេះគាត់បានដាក់ឈ្មោះឲ្យកូនគាត់ថា អ៊ីសាក មានន័យថា “សំណើច” ហើយវាជាការល្អដែលមានអារម្មណ៍រីករាយ។ សេចក្ដីសន្យារបស់ព្រះនាំមកនូវអំណរដល់យើង។

ព្រះបានប្រទានពរដល់យើងនូវអ្វីៗជាច្រើនដែលនាំឱ្យយើងមានក្ដីអំណរ។ ព្រះបានប្រទានពរឲ្យយើងមានក្រុមគ្រួសារដែលស្រឡាញ់យើង ហើយអោបក្រសោបយើង។ ព្រះប្រទានអាហារដល់យើង។ ព្រះប្រទានពររូបកាយដ៏រឹងមាំដល់យើងដែលអាចរត់លេងបាន។ សប្ដាហ៍នេះសូមចំណាយពេលយកចិត្តទុកដាក់ចំពោះអ្វីៗដែលធ្វើឲ្យយើងញញឹម និងធ្វើឲ្យយើងរីករាយ។ សូមចំណាយពេលក្នុងការអរព្រះគុណព្រះសំរាប់អ្វីៗដែលរីករាយ។ សូមចងចាំថា! ក្ដីសន្យារបស់ព្រះនាំមកនូវក្ដីអំណរ!

## ៦. សំនួរពិភាក្សា

១. ឈ្មោះ អ៊ីសាក មានអត្ថន័យដូចម្ដេច? *សំណើច*

២. ហេតុអ្វីបានជាអ័ប្រាហាំ និង សារ៉ា ដាក់ឈ្មោះកូនគាត់ថាអ៊ីសាក?

*ពីព្រោះព្រះបានប្រទានពរ ក្ដីអំណរដល់ពួកគេតាមរយៈការប្រទានកូនឲ្យដល់ពួកគេ*

៣. តើអ្វីជាអំណរសំរាប់អ្នកក្នុងសប្ដាហ៍នេះ? *សូមឲ្យកុមារឆ្លើយ*

## ៧. ល្បែងកំសាន្ត «អធិស្ឋាន» «រាំ និងច្រៀងតម្កើងព្រះ» «អរព្រះគុណ» ឬក៏ «សើច»




**សម្ភារៈដែលត្រូវការ៖** ក្រដាស A4 ៤សន្លឹក ដែលសរសេរពាក្យថា “អធិស្ឋាន” “រាំ និងច្រៀងសរសើរតម្កើងព្រះ” “អរគុណព្រះ” “សើច” និងតុ ១

១. គ្រូត្រូវបិតក្រដាសទាំង៤ សន្លឹកនៅលើជញ្ជាំង ត្រង់ទីតាំងខុសៗគ្នា (មិនឲ្យកុមារឃើញពាក្យខាងក្នុងទេ)។

២. កុមារត្រូវរាំនៅជុំវិញតុ (ឬកៅអី) ដោយចាក់ភ្លេង ហើយនៅពេលដែលភ្លេងឈប់ កុមារត្រូវរត់ទៅកាន់ជ្រុងជញ្ជាំងដែលបិតក្រដាសណាមួយក៏បាន។

៣. កុមារត្រូវតែធ្វើតាមពាក្យដែលបានបិតនោះ។ ឧទាហរណ៍៖ ប្រសិនបើគេរត់ទៅរកជញ្ជាំងដែលមានបិតពាក្យថា “អធិស្ឋាន” ពួកគេត្រូវអធិស្ឋាន។ ហើយប្រសិនបើពួកគេរត់ទៅរកជញ្ជាំងដែលមានពាក្យថា “រាំ ច្រៀង សរសើរតម្កើងព្រះ” ពួកគេត្រូវរាំ។




៤. លេងល្បែងនេះក្នុងរយៈពេល ១ នាទី។

៥. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា ព្រះតែងតែចង់ឲ្យយើងមានអំណរ។ ព្រះប្រទានពរឲ្យយើងនូវអំណរ ដូច្នេះហើយយើងនឹងអាចអរសប្បាយ។ សូមយកចិត្តទុកដាក់ឲ្យប្រាកដជាមួយអ្វីល្អៗ ដែលព្រះបានធ្វើសំរាប់យើង ដូច្នេះហើយយើងអាចនឹងមានអំណរ!

| | |
|---|---|
| **៨. ខគម្ពីរចងចាំ** | ***ភីលីព ៤:៤*** |

| | |
|---|---|
| **៩. ហត្ថកម្ម** | **«ព្រះប្រទានអំណរដល់យើង»** |

**សម្ភារៈដែលត្រូវការ៖** បោះពុម្ពក្រដាសហត្ថកម្ម កូល័រផាត់ពណ៌ កន្ត្រៃ និងការ៉បិត



១. ចែកក្រដាសហត្ថកម្មឲ្យកុមារម្នាក់១សន្លឹក ហើយឲ្យកុមារផាត់ពណ៌ក្រដាសហត្ថកម្មនោះ។

២. កាត់ប្រអប់ដែលមានរូបអ័ប្រាហាំ និងសារ៉ាចេញមក។ បន្ទាប់មកកាត់រូបទារក ហើយបិតរូបទារកនោះ នៅក្នុងអង្រឹង។

៣. សូមចាំថា ព្រះតែងតែប្រទានពរដល់យើងនូវអំណោយល្អៗ ដូច្នេះហើយយើងអាចនឹងមានអំណរជានិច្ច!

**១០. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**១១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបិទ)*

## ព្រះប្រទានពរអំណរដល់យើង!

សម្ភារៈដែលត្រូវការ៖ បោះពុម្ពក្រដាសហត្ថកម្ម
កូល័រ កន្ត្រៃ និងកាវបិត

១. ចែកក្រដាសហត្ថកម្មឲ្យកុមារម្នាក់១សន្លឹក ហើយឲ្យកុមារផាត់ព៌ណក្រដាសហត្ថកម្មនោះ រួមទាំងរូបទារក

២. កាត់ប្រអប់ដែលមានរូបអ័ប្រាហាំ និងសារ៉ាចេញមក។ បន្ទាប់មកកាត់រូបកូនទារក ហើយបិតរូបនោះនៅក្នុងកូនអង្រឹង។

៣. សូមចាំថា ព្រះតែងតែប្រទានពរដល់យើងនូវអំណោយល្អៗ ដូច្នេះហើយយើងអាចនឹងមានអំណរជានិច្ច។





## ព្រះប្រទានពរអំណរដល់យើង!

សម្ភារៈដែលត្រូវការ៖ បោះពុម្ពក្រដាសហត្ថកម្ម
កូល័រ កន្ត្រៃ និងកាវបិត

១. ចែកក្រដាសហត្ថកម្មឲ្យកុមារម្នាក់១សន្លឹក ហើយឲ្យកុមារផាត់ព៌ណក្រដាសហត្ថកម្មនោះ រួមទាំងរូបទារក

២. កាត់ប្រអប់ដែលមានរូបអ័ប្រាហាំ និងសារ៉ាចេញមក។ បន្ទាប់មកកាត់រូបកូនទារក ហើយបិតរូបនោះនៅក្នុងកូនអង្រឹង។

៣. សូមចាំថា ព្រះតែងតែប្រទានពរដល់យើងនូវអំណោយល្អៗ ដូច្នេះហើយយើងអាចនឹងមានអំណរជានិច្ច។



